# ការណែនាំអំពីការដំឡើង
# DRC-001



# I. សេចក្តីផ្តើម

ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-001 ដែលបានអភិវឌ្ឍឡើងដោយក្រុមហ៊ុន VP.Start ប្រើសម្រាប់បញ្ជាផ្តាច់ភ្ជាប់ Switchgear របស់ Auto Recloser Schneider ។ DRC-001 បានធ្វើទំនើបកម្មលើវិស័យគ្រប់គ្រងថាមពលអគ្គិសនីតង់ស្យុងមធ្យម 22kV និង 35kV ឲ្យកាន់តែមានប្រសិទ្ធភាព និង ងាយស្រួលលើការត្រួតពិនិត្យតាមដាន និងបញ្ជាលើបណ្តាញ ចែកចាយថាមពលអគ្គិសនី ។ ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-001 បានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់អតិថិជនដែលជាអ្នកផ្គត់ផ្គង់អគ្គិសនី និងអ្នកបច្ចេកទេសតាមរយៈការទទួលបាន ព័ត៌មានកំហូចភ្លាមៗ នៅពេលបណ្តាញចែកចាយថាមពលអគ្គិសនីមានបញ្ហា កាន់តែងាយស្រួលស្វែងរកមូលហេតុទីតាំងដែលមានបញ្ហា ជាពិសេសគឺចំណេញពេលវេលាក្នុង ការជួសជុល ក៏ដូចជាកាត់បន្ថយរយៈពេលដាច់ចរន្តអគ្គិសនីដល់អតិថិជន និងងាយស្រួលក្នុងការថែទាំបណ្តាញប្រកបដោយសុវត្ថិភាព ។ ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-001 ក៏អនុញ្ញាតឲ្យយើងត្រួតពិនិត្យមើល តង់ស្យុង ចរន្តអានុភាព កត្តាអនុភាព ថាមពល បន្ទុកប្រើប្រាស់ និងការបាត់បង់ ថាមពលអគ្គិសនីភ្លាមៗ ដែលធ្វើឲ្យកាន់តែចំណេញដល់ម្ចាស់អាជីវកម្ម ។

# II. គ្រឿងបរិក្ខារ




ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-001 ចំនួន ១



ជើងទម្រឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-001 ចំនួន ១



អង់តែន GSM ចំនួន ១



ខ្សែបញ្ជូនទិន្នន័យ (Male to Female) ចំនួន ១



ខ្សែភ្លើងចរន្តជាប់ ចំនួន ១



ឧបករណ៍ចាប់សញ្ញាពេលមានទ្វាចំហ ចំនួន ១



ខ្សែចំណងជ័រ ចំនួន ៦



វីសមានក្បាលខ្មៅ ចំនួន ២



វីស សម្រាប់ភ្ជាប់ជាមួយឌីស្យុងទ័រ ២២០វ៉ុល (AC 220V CB) ចំនួន ១

# III. ការដំឡើង

## សម្ភារសម្រាប់ដំឡើង



អូមម៉ែត្រ



ទួណឺវីសមុខ ៤



សោ L ៨មម



ដង្កាប់កាត់ខ្សែភ្លើង

# ដំណើរការដំឡើង DRC-001

01 បំពាក់ជើងទម្រឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ នៅលើជើងទម្រក្នុងទូបញ្ជា ADVC របស់ Auto Recloser ។



02 បំពាក់ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយនៅលើជើងទម្រ ។




03 វាស់តង់ស្យុងចរន្តជាប់រវាងប៉ូល បូក (+) និង (GND) នៅលើឆ្នាប់ចរន្តដែលមាននៅក្នុងទូបញ្ជា ADVC ដោយប្រើប្រាស់អូមម៉ែត្រ ។




**⚠ ចំណាំ**

- តង់ស្យុងសម្រាប់ដំណើរការឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយចន្លោះពី 12-29 Vdc ។

04 ភ្ជាប់ខ្សែភ្លើងចរន្តជាប់ទៅនឹងឆ្នាប់ចរន្ត ដោយខ្សែពណ៌ក្រហមភ្ជាប់ទៅប៉ូលបូក ( + ) និង ខ្សែពណ៌ខ្មៅភ្ជាប់ទៅ (GND) ។



05 ដោតឌុយខ្សែភ្លើងចរន្តជាប់ទៅក្នុងរន្ធ 24V ដែលស្ថិតនៅលើ ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយចំហៀងខាងស្តាំ ។




06 ភ្ជាប់ខ្សែបញ្ជូនទិន្នន័យ ( Female ) ជាមួយនឹង RS232 Port A នៅលើ ADVC Controller ។



07 ភ្ជាប់ខ្សែបញ្ជូនទិន្នន័យ (Male) ជាមួយនឹង RS232 នៅលើ ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ ។




08 ចាប់បញ្ចូល វីសជាមួយនឹងឌីស្យុងទ័រ ២២០វ៉ុល (AC 220V CB) ។



09 ភ្ជាប់ឧបករណ៍ចាប់សញ្ញាទ្វាចំហជាប់ផ្នែកខាងឆ្វេង ឌីស្យុងទ័រ ២២០វ៉ុល (AC 220V CB) ។



10 ដោតខ្សែឧបករណ៍ចាប់សញ្ញាទ្វាចំហក្នុងរន្ធ SW នៅលើឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ ។




11 ដំឡើងអង់តែន GSM នៅទីតាំងដែលអាចចាប់សេវាទូរស័ព្ទបានល្អ ។



**⚠ ចំណាំ**

- ទីតាំងអង់តែន GSM ត្រូវតែដាក់នៅទីតាំងដែលអាចទទួលសេវាបានល្អ ។

12 ភ្ជាប់ខ្សែអង់តែន GSM ទៅកាន់រន្ធ ANT នៅលើឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-001 ។



**13** ដាក់បញ្ចូលស៊ីមកាត ក្នុងរន្ធដាក់ស៊ីមកាតនៅលើ ឧបករណ៍បញ្ជាផ្ដាច់ភ្ជាប់ពីចម្ងាយ DRC-001 ។




**14** ចុចប៊ូតុងដើម្បីបើកភ្លើងដំណើរការឧបករណ៍បញ្ជា ផ្ដាច់ភ្ជាប់ពីចម្ងាយ DRC-001 ។




### ⚠ ចំណាំ

- ឧបករណ៍បញ្ជាផ្ដាច់ភ្ជាប់ពីចម្ងាយ DRC-001 ដំណើរការធម្មតា Running LED ភ្លឺបភ្លែតៗ រៀងរាល់ ១វិនាទី ។
- សេវា GSM (GSM Connection) ដែលធ្វើការត្រឹមត្រូវ Net LED ភ្លឺបភ្លែតៗ រៀងរាល់ ៣វិនាទី ។
- GSM Module ដំណើរការធម្មតា GSM LED ភ្លឺជាប់ ។

**15** ចុចបើក (Enable) ប៊ូតុង TRIP CIRCUIT និង CLOSE CIRCUIT ។



**16** កំណត់ប៉ារ៉ាម៉ែត្រ RS232-Port A ជា LOCAL Mode នៅលើ ADVC Controller របស់ Auto Recloser ៖

> COMMUNICATION SETUP
> Configure Ports
> RS232-Port-A
> Mode LOCAL




**17** កំណត់ប៉ារ៉ាម៉ែត្រ OPERATOR SETTING ជា LOCAL CONTROL ON នៅលើ ADVC Controller របស់ Auto Recloser ៖

> COMMUNICATION SETUP
> OPERATOR SETTINGS1
> LOCAL CONTROL ON



sale@vpstart.com | info@vpstart.com (+855) 23 888 167 | (+855) 86 666 677